អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

# សេចក្តីប្រកាសរបស់សហព្រះរាជអាជ្ញាអន្តរជាតិ Andrew Cayley

ដោយបានដាក់លិខិតលាលែងពីតំណែងរបស់ខ្ញុំជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិនៅខែសីហា ឆ្នាំ ២០១៣ ខ្ញុំនឹងលាឈប់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) នៅថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៣ ខាងមុខនេះ ដោយសារមូលហេតុផ្ទាល់ខ្លួន។ ខ្ញុំនឹងទៅរស់នៅជាមួយគ្រួសារខ្ញុំ ដែលបានត្រឡប់មកពីប្រទេសកម្ពុជាវិញកាលពីខែមិថុនា ឆ្នាំ ២០១៣។ តាមការរំពឹងទុក សហព្រះរាជអាជ្ញាអន្តរជាតិបម្រុង Nicholas Koumjian នឹងមកដល់ប្រទេសកម្ពុជា នៅខែតុលា ឆ្នាំ ២០១៣។

ខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលិកទាំងអស់នៃការិយាល័យសហព្រះរាជអាជ្ញា ដែលបានខិតខំប្រឹងប្រែងធ្វើការងាររបស់ពួកគាត់ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ។ ក្នុងនាមជាស្ថាប័នតុលាការមួយ និងជាការិយាល័យមួយ យើងបានប្រឈមមុខជាមួយនឹងកិច្ចការលំបាកជាច្រើនជាមួយគ្នា។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់លោកស្រី ជា លាង សហព្រះរាជអាជ្ញាជាតិ លោក យ៉េត ចរិយា សហព្រះរាជអាជ្ញារងជាតិ និងលោក William Smith សហព្រះរាជអជ្ញារងអន្តរជាតិ ដែលបានផ្តល់បរិយាកាសការងារប្រកបដោយសហប្រតិបត្តិការ និងមិត្តភាព ក្នុងពេលដែលយើងបានធ្វើការជាមួយគ្នា។

ខ្ញុំសូមជូនពរឲ្យតុលាការនេះដំណើរការទៅមុខបានល្អ ហើយខ្ញុំពិតជាសង្ឃឹមថា បញ្ហាហិរញ្ញវត្ថុបន្ទាន់មួយចំនួនដែលតុលាការកំពុងប្រឈមមុខ នឹងអាចដោះស្រាយបានដើម្បីឲ្យសំណុំរឿងបញ្ចប់បានតាមត្រឹមត្រូវ និងតាមពេលវេលាសមស្រប។ ខ្ញុំមានកិត្តិយសណាស់ដែលបានចូលរួមជាផ្នែកមួយនៃដំណើរការប្រវត្តិសាស្ត្រនេះក្នុងការនាំមកនូវយុត្តិធម៌ជូនប្រជាជនកម្ពុជា។